

# វ៉ាក់សាំង COVID-19
# អ្វីដែលឪពុកម្តាយត្រូវស្វែងយល់




## តើកូនរបស់ខ្ញុំអាចចាក់វ៉ាក់សាំងបង្ការជំងឺ COVID-19 បានដែរឬទេ?

**កុមារដែលមានអាយុចាប់ពី 12 ឡើងទៅអាចចាក់វ៉ាក់សាំងរបស់ Pfizer បាន។**

- វ៉ាក់សាំងគឺ**ឥតគិតថ្លៃ**សម្រាប់មនុស្សគ្រប់គ្នា។
- អ្នកមិនចាំបាច់មានការធានារ៉ាប់រងទេ។
- អ្នកនឹងមិនត្រូវបានសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។
- មនុស្សគ្រប់គ្នាអាចចាក់វ៉ាក់សាំងបាន រួមទាំងមនុស្សភាគច្រើនដែលមានអាឡែរហ្ស៊ីផងដែរ។



## តើខ្ញុំគួរយកកូនរបស់ខ្ញុំទៅចាក់ថ្នាំបង្ការជំងឺ COVID-19 ដែរឬទេ?

- ត្រឹមត្រូវ! វ៉ាក់សាំងបង្ការជំងឺ COVID-19 **មានសុវត្ថិភាព និងមានប្រសិទ្ធភាព**។
- ការឆ្លងជំងឺ COVID-19 ច្រើនតែស្រាលចំពោះកុមារ ប៉ុន្តែកុមារមួយចំនួនអាចឈឺខ្លាំង ឬមានបញ្ហាសុខភាពយូរអង្វែង។
- កុមារអាចចម្លងវីរុសដល់អ្នកដទៃ។ ជួយការពារក្រុមគ្រួសាររបស់អ្នកដោយទទួលការចាក់ថ្នាំបង្ការសម្រាប់ខ្លួនអ្នកផ្ទាល់ និងកូនៗរបស់អ្នក។



## តើខ្ញុំអាចយកកូនរបស់ខ្ញុំទៅចាក់វ៉ាក់សាំងនៅទីណាបាន?

សួរគ្រូពេទ្យកូនរបស់អ្នក ឱសថស្ថានក្នុងតំបន់ ឬចូលទៅកាន់គេហទំព័រ **VaccinateLACounty.Com** ដើម្បីស្វែងរកកន្លែងចាក់វ៉ាក់សាំងនៅជិតអ្នក។ រកមើលគ្លីនិកចាក់វ៉ាក់សាំងដែលមានរៀបចំធ្វើឡើងនៅសាលាកូនរបស់អ្នក។

**មិនចាំបាច់ធ្វើការណាត់ជួបទេ**នៅតាមទីតាំងជាច្រើន។

សូមទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលចាក់វ៉ាក់សាំង DPH តាមរយៈលេខ **833-540-0473** ប្រសិនបើអ្នកត្រូវការជំនួយក្នុងការស្វែងរកវ៉ាក់សាំង ត្រូវការការដឹកជញ្ជូនទៅទីតាំងចាក់វ៉ាក់សាំង ឬស្នើសុំការចាក់វ៉ាក់សាំងនៅតាមផ្ទះសម្រាប់កុមារដែលមិនអាចធ្វើដំណើរចេញពីផ្ទះបាន។ បើកបម្រើការជូនជារៀងរាល់ថ្ងៃ ចាប់ពីម៉ោង 8:00ព្រឹក ដល់ម៉ោង 8:30យប់។

ព័ត៌មានមានជាច្រើនភាសាដោយបម្រើការ 24/7 ដោយទូរស័ព្ទទៅកាន់ 2-1-1។

## តើមានផលប៉ះពាល់អ្វីខ្លះ?

- កុមារទទួលការចាក់វ៉ាក់សាំងការពារដូចគ្នានៃចំនួនដូស ហើយក៏មានអាការៈប៉ះពាល់ដូចគ្នានឹងមនុស្សពេញវ័យផងដែរ។
- ផលប៉ះពាល់នោះរួមមានទាំង ការឈឺដៃ ឬឡើងក្រហមដៃ មានអារម្មណ៍នឿយហត់ គ្រុនក្តៅ រងាររញ្ញាក់ ឈឺក្បាល ឬឈឺសាច់ដុំ។ មិនមែនមនុស្សគ្រប់គ្នានឹងកើតមានផលប៉ះពាល់ទាំងនេះទេ។
- ផលប៉ះពាល់គឺជារឿងធម្មតា ហើយជាសញ្ញាបង្ហាញថាប្រព័ន្ធភាពស៊ាំលើរាងកាយកូនរបស់អ្នកគឺ **កំពុងរៀបចំប្រព័ន្ធការពារ**។
- អាការៈទាំងនេះគឺអាចធ្វើឱ្យមានផលប៉ះពាល់ដល់សមត្ថភាពបំពេញការងារប្រចាំថ្ងៃចំពោះកូនរបស់អ្នក ប៉ុន្តែអាការៈទាំងនេះនឹងបាត់ទៅវិញក្នុងរយៈពេលពីរទៅបីថ្ងៃក្រោយ។



**VaccinateLACounty.com**

**(Cambodian)**

County of Los Angeles Public Health

6-28-21

# វ៉ាក់សាំង COVID-19
# អ្វីដែលឪពុកម្តាយត្រូវស្វែងយល់

## តើវ៉ាក់សាំងបង្ការជំងឺ COVID-19 មានសុវត្ថិភាពសម្រាប់កុមារដែរឬទេ?

- កូនរបស់អ្នកមិនកើតជំងឺ COVID-19 ពីវ៉ាក់សាំងនេះទេ។ គ្មានវ៉ាក់សាំងណាមួយមានផ្ទុកវីរុសដែលបង្កឱ្យមានជំងឺCOVID-19នោះទេ។
- វ៉ាក់សាំងទាំងនេះត្រូវបានធ្វើតេស្តលើមនុស្សរាប់ម៉ឺននាក់ រួមមានមនុស្សគ្រប់កម្រិតអាយុ មនុស្សដែលមានពណ៌សម្បុរផ្សេងៗ និងមនុស្សដែលមានបញ្ហាសុខភាព ហើយរកឃើញថាគឺមានសុវត្ថិភាព។
- គ្រប់ជំហានគឺទាមទារឱ្យមានភាពប្រាកដប្រជាដើម្បីធ្វើឱ្យវ៉ាក់សាំងមាន **សុវត្ថិភាព និងប្រសិទ្ធិភាព**។
- មនុស្សមួយចំនួនតូច ដែលភាគច្រើនជាមនុស្សវ័យជំទង់ និងមនុស្សពេញវ័យមានការរលាកសាច់ដុំបេះដូង (ជំងឺរលាកបេះដូង និងជំងឺរលាកសរសៃឈាមបេះដូង) បន្ទាប់ពីបានចាក់វ៉ាក់សាំង Pfizer ឬ Moderna។ បញ្ហានេះពិតជាកម្រកើតមានណាស់។ ករណីភាគច្រើនមានលក្ខណៈស្រាលហើយឆាប់ជាសះស្បើយដោយគ្រាន់តែមានការព្យាបាលនិងសម្រាកគ្រប់គ្រាន់។ ជំងឺរលាកបេះដូង និងជំងឺរលាកសរសៃឈាមបេះដូងជាទូទៅកើតឡើងចំពោះមនុស្សដែលមានជំងឺ COVID-19 ហើយហានិភ័យចំពោះបេះដូងដោយការឆ្លងជំងឺ COVID-19 អាចមានសភាពធ្ងន់ធ្ងរជាងនេះ។ **អត្ថប្រយោជន៍នៃវ៉ាក់សាំងគឺមានច្រើនជាងហានិភ័យ**។
- មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថាវ៉ាក់សាំងបង្ការជំងឺ COVID-19 ជះឥទ្ធិពលដល់ការវិវត្តរបស់មនុស្សពេញវ័យ ឬសមត្ថភាពបន្តពូជឡើយ។
- ប្រសិនបើអ្នកមានសំណួរឬកង្វល់ សូមពិគ្រោះជាមួយគ្រូពេទ្យរបស់កូនអ្នក។










## មុនពេលកូនរបស់អ្នកចាក់ថ្នាំបង្ការ

- និយាយជាមួយកូនរបស់អ្នកអំពីវ៉ាក់សាំង ផលប៉ះពាល់ដែលអាចកើតមាន និងអ្វីដែលត្រូវរំពឹងទុកនៅឯទីតាំងវ៉ាក់សាំងរបស់ពួកគេ។
- ត្រូវប្រាកដថាកន្លែងចាក់វ៉ាក់សាំងនោះមានផ្តល់វ៉ាក់សាំងប្រភេទ Pfizer។
- ពិនិត្យមើលដើម្បីយល់ពីរបៀបនៃតម្រូវការលើ**កិច្ចព្រមព្រៀងរបស់ឪពុកម្តាយ**។
- ទទួលព័ត៌មានអំពីវ៉ាក់សាំងផ្សេងទៀតសម្រាប់កូនរបស់អ្នក។ វ៉ាក់សាំងបង្ការជំងឺ COVID-19 អាចត្រូវបានផ្តល់ឱ្យក្នុងពេលតំណាលគ្នាមុនពេល ឬក្រោយពេលចាក់វ៉ាក់សាំងដែលប្រើជាធម្មតាផ្សេងទៀត។

## បន្ទាប់ពីចាក់ថ្នាំបង្ការរួច

- កូនរបស់អ្នក**បានចាក់វ៉ាក់សាំងពេញលេញ**គឺ 2 សប្តាហ៍បន្ទាប់ពីពួកគេបានចាក់លើកទីពីរនៃប្រភេទវ៉ាក់សាំងPfizer។ វាត្រូវការពេលវេលាក្នុងការធ្វើឱ្យរាងកាយបង្កើតភាពស៊ាំ។
- នៅពេលដែលកូនរបស់អ្នកត្រូវបានចាក់វ៉ាក់សាំងពេញលេញ ពួកគេនឹងត្រូវបានការពារនៅពេលពួកគេទៅលេងជាមួយមិត្តភក្តិ លេងកីឡា ធ្វើដំណើរទៅជួបគ្រួសារ និងពេលត្រឡប់ចូលរៀនតាមសាលាវិញ។
- ប្រសិនបើកូនរបស់អ្នកត្រូវបានចាក់វ៉ាក់សាំងពេញលេញ ពួកគេមិនចាំបាច់ដាក់ឱ្យនៅដាច់ដោយឡែក (ចត្តាឡីស័ក) ប្រសិនបើមិត្តភក្តិសមាជិកគ្រួសារ គ្រូ ឬមិត្តរួមក្រុមមានជំងឺ COVID-19នោះ។



**VaccinateLACounty.com**
**(Cambodian)**

County of Los Angeles
**Public Health**
6-28-21